# សេចក្តីប្រកាសព័ត៌មាន

## កិច្ចប្រជុំរៀបចំចាប់ផ្តើមអនុវត្តការធ្វើប្រតិភូកម្មអំណាចនៃការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម និងសេវាកម្ម

### ថ្ងៃសុក្រ ទី១៩ ខែធ្នូ ឆ្នាំ២០១៤

### សាលប្រជុំបាយ័ន ទីស្តីការក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ក្នុងគោលបំណងបន្តជំរុញការអនុវត្តតាមខ្លឹមសារសេចក្តីជូនដំណឹងលេខ ៥១៦ សជណ.សរ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីលទ្ធផលនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៧ ឱ្យមានប្រសិទ្ធភាព និងទទួលបានផ្លែផ្កាពិតប្រាកដ ក្នុងការចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម និងសេវាជូនដល់ធុរជន កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានបើកកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងរៀបចំចាប់ផ្តើមអនុវត្តការធ្វើប្រតិភូកម្មអំណាចនៃការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម និងសេវាកម្ម ពីបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយមានសមាសភាពចូលរួមពីថ្នាក់ដឹកនាំតំណាងក្រសួង-ស្ថាប័ននានា ដូចជា ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរ៉ែ និងថាមពល ក្រសួងសុខាភិបាល ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ក្រសួងទេសចរណ៍ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងព័ត៌មាន ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរអគ្គិសនីកម្ពុជា។

កិច្ចប្រជុំនាពេលនេះ មានសារៈសំខាន់ណាស់ ក្នុងការស្វែងរករូបមន្ត ឬដំណោះស្រាយ ដើម្បីអនុវត្តឱ្យខាងតែបាននូវការសម្រេចរបស់រាជរដ្ឋាភិបាល ដែលតម្រូវឱ្យមានការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម និងសេវា ប្រមូលផ្តុំនៅបញ្ច្រកចេញចូលតែមួយរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយចង់បញ្ចប់វប្បធម៌ ឬទម្លាប់ចាស់ដូចបច្ចុប្បន្ននេះ ដែលតម្រូវឲ្យម្ចាស់សហគ្រាសទៅគោះទ្វារតាមបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីស្នើសុំអាជ្ញាប័ណ្ណ ឬការយល់ព្រមផ្សេងៗ។ នេះគឺជាការឆ្លើយតបទៅនឹងសំណូមពរដ៏ទទូចរបស់វិស័យឯកជន ដែលចង់បាន ចង់ឃើញការផ្តល់សេវារដ្ឋបាលសាធារណៈប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងភាពអាចជឿទុកចិត្តបាន ហើយក៏ជាផ្នែកមួយនៃកំណែទម្រង់ការងារស៊ីជម្រៅរបស់រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៥ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ឯកសារសេចក្តីព្រាងសំខាន់ៗចំនួន៣ ដែលបានលើកយកមកពិភាក្សា ដូចខាងក្រោម៖

*១- ប្រកាសស្តីពីប្រតិភូកម្មអំណាចការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម និងសេវាជូនក្រសួងឧស្សាហកម្ម និងសិប្បកម្ម*

*២- សេចក្តីណែនាំស្តីពីការអនុវត្តប្រកាស ការធ្វើប្រតិភូកម្ម នៃការចុះបញ្ជីសហគ្រាសធុនតូច-មធ្យម និងសេវា*

*៣- តារាងប្រភេទសេវា និងតម្លៃសេវាសំរាប់ការងារចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម និងសេវា*

**លទ្ធផលកិច្ចប្រជុំ៖**

អង្គប្រជុំបានឯកភាព ក្នុងការបន្តចូលរួមអនុវត្តការធ្វើប្រតិភូកម្មនៃការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម និងសេវាឲ្យស្ថិតនៅក្រោមយន្តការក្របខណ្ឌដំបូលតែមួយរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការចូលរួមកែលម្អ និងធ្វើឲ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ចនៅកម្ពុជា។ ជាពិសេសការកែលម្អបរិយាកាសធុរកិច្ចនេះ គឺដើម្បីត្រៀមឱកាសទាក់ទាញទុនវិនិយោគធំៗពីបរទេស ក្នុងបរិបទនិន្នាការធ្វើ សមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន ឆ្នាំ ២០១៥ និងការបង្កើតឱកាសល្អប្រសើរសម្រាប់ការវិនិយោគ ពីវិស័យឯកជននៅក្នុងប្រទេស។

**ទិសដៅ៖**

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងបន្តជំរុញលើការធ្វើប្រតិភូកម្មនៃការចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម និងសេវា ឲ្យស្ថិតនៅក្រោមយន្តការក្របខណ្ឌដំបូលតែមួយ ដោយមានការសហការយ៉ាងជិតស្និតពីបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តការងារនេះឲ្យទទួលបានជោគជ័យ ជាបន្តបន្ទាប់។









